ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ........................................................

# សេចក្តីប្រកាសព័ត៌មាន

នៅព្រឹកថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ២០១៤ ធនាគារជាតិនៃកម្ពុជាបានសម្របសម្រួលកិច្ចពិភាក្សាមួយ ស្តីអំពី "ការដោះស្រាយបញ្ហាដែលកើតមានឡើងក្នុងប្រតិបត្តិការសភាផាត់ទាត់រវាងធនាគារ និងធនាគារ" ក្រោមអធិបតីភាពរបស់លោកជំទាវអគ្គនាយកបច្ចេកទេសនៃធនាគារជាតិនៃកម្ពុជា ។ សមាសភាពដែលបានចូលរួមមាន គ្រប់សមាជិកសភាផាត់ទាត់ទាំងអស់ និងតំណាងធនាគារជាតិនៃកម្ពុជា ។

ក្នុងគោលដៅដើម្បីជំរុញប្រសិទ្ធភាពការងារសភាផាត់ទាត់ អង្គប្រជុំបានលើកឡើងកត្តាសំខាន់ៗពីរ រួមមាន (i) ការជំរុញឲ្យមានការទូទាត់ជាលក្ខណៈអេឡិចត្រូនិក និងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល និង (ii) ការកាត់បន្ថយការបង្វិលវិញនូវមូលប្បទានប័ត្រ ។ ជុំវិញបញ្ហាខាងលើ ធនាគារពាណិជ្ជទាំងអស់ត្រូវណែនាំដល់អតិថិជនរបស់ខ្លួនអំពីការប្រើប្រាស់ និងអត្ថប្រយោជន៍នៃការទូទាត់ជាលក្ខណៈអេឡិចត្រូនិក ។ លោកជំទាវអគ្គនាយកបច្ចេកទេសក៏បានសង្កត់ធ្ងន់លើតម្លាភាពនៃការយកកម្រៃជើងសារក្នុងការទូទាត់ និងជំរុញឲ្យមានការកំនត់ជាស្តង់ដារមួយ ។ លើសពីនេះ ធនាគារនីមួយៗត្រូវណែនាំដល់អតិថិជនរបស់ខ្លួនឲ្យមានការប្រុងប្រយ័ត្នក្នុងការចេញមូលប្បទានប័ត្រពោលគឺកុំឲ្យមានកំហុសឆ្គងកើតឡើង ។ ជារួម កិច្ចពិភាក្សានេះពិតជាមានសារសំខាន់សម្រាប់ការអភិវឌ្ឍន៍សភាផាត់ទាត់ និងជាចំណែកចូលរួមលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលដោយជំរុញឲ្យមានការទូទាត់ជាលក្ខណៈអេឡិចត្រូនិក ដែលធ្វើឲ្យប្រព័ន្ធទូទាត់នៅកម្ពុជាកាន់តែមានប្រសិទ្ធភាព។

ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧